# «ឌុច គឺជាដៃគូរដ៏មានឆន្ទៈមោះមុតម្នាក់»

**សាស្ត្រាចារ្យ ដេវីត សេហ្វហ្វឺ**

**ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៩**

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

ថ្ងៃនេះ សហព្រះរាជអាជ្ញា បានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់ខ្លួននៅក្នុងអង្គជំនុំជម្រះសេចក្តីប្រឆាំង កាំង ហ្កេកអ៊ាវ (ហៅ ឌុច) ហើយនឹងបន្តបញ្ចប់សេចក្តីសន្និដ្ឋានរបស់ខ្លួននៅថ្ងៃស្អែក ។ ភាពច្របូកច្របល់តែមួយគត់ដែលបានកើតឡើងនៅក្នុងបន្ទប់សវនាការ គឺមានមន្ត្រីតុលាការម្នាក់បានដួលសន្លប់ ដែលបណ្តាលឲ្យមានការពន្យាពេលខ្លីមួយនៅក្នុងដំណើរការនីតិវិធី ។ ជាមួយគ្នានេះ បញ្ហាប្រព័ន្ធសម្លេងដែលបានកើតឡើងនៅពេលរសៀល ក៏បានធ្វើឲ្យមានការពន្យាពេលបន្តិចទៀតដែរ ។ មួយរយៈពេលក្រោយមក មន្ត្រីតុលាការដែលដួលសន្លប់នោះក៏បានវិលត្រឡប់មកអង្គុយធ្វើការមួយរយៈពេលខ្លីម្តងទៀត ។ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានអានសេចក្តីសន្និដ្ឋានដាច់ដោយឡែករបស់ខ្លួន ដែលជាសេចក្តីសង្ខេបពីសេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សរដែលមានចំនួនសរុប១៦០ទំព័រជូនអង្គសវនាការបានជ្រាប ។ ដូច្នេះ វាគឺជាថ្ងៃអានសេចក្តីសន្និដ្ឋានដែលរៀបចំទុក មានបញ្ជាក់ពីការពន្យល់លម្អិតបន្ថែមពីឧក្រិដ្ឋកម្ម និងច្បាប់ដែលភ្ជាប់ជាមួយនឹងការយល់ដឹងពីអត្តចរិក និងឆន្ទះរបស់ជនត្រូវចោទ ឌុច ដែលជាឧក្រិដ្ឋជនសង្គ្រាម ។

ក្នុងអំឡុងពេលពេញមួយថ្ងៃ បន្ទប់សវនាការពោរពេញដោយសិស្សវិទ្យាល័យដែលស្ថិតនៅក្នុងសម្ពៀកបំពាក់ឯកសណ្ឋាន ហើយនិងមាន ដូនជី ជនជាតិចាម និងក្រុមជនរងគ្រោះ (រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី)ផងដែរ ។ ខ្ញុំបានសម្លឹងមើលមុខរបស់ក្មេងៗទាំងនោះ និងឆ្ងល់ថា តើក្មេងៗទាំងនោះអាចចងចាំអ្វីខ្លះនៅថ្ងៃនេះ និងតើក្នុងចំណោមពួកគេមានប៉ុន្មាននាក់ដែលអាចរៀបរាប់ពីរឿងរ៉ាវអាក្រក់ៗដែលបានកើតឡើងចំពោះសមាជិកគ្រួសាររបស់គេកាលពី៣០ឆ្នាំមុន ។ នៅពេលដែលតុលាការនេះត្រូវបានបញ្ចប់ទៅ យើងរំពឹងទុកថា តុលាការនេះអាចនឹងសម្រេចឲ្យមានការចូលរួមតាមដានដំណើរការរបស់តុលាការពីសំណាក់ជនរងគ្រោះរបស់តុលាការឧក្រិដ្ឋកម្មសង្គ្រាមផ្សេងទៀត ។ សេចក្តីសម្រេចមួយភាគធំរបស់កិច្ចការនេះ ត្រូវបានផ្តល់ជូនដល់ការខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្រោមការដឹកនាំរបស់លោក ឆាំង យុ ។

## ដា លាង សហព្រះរាជអាជ្ញាជាតិ

ដា លាង ដែលជាសហព្រះរាជអាជ្ញាជាតិ បានចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោល អស់រយៈពេលជាច្រើនម៉ោង ដោយដំបូងគឺធ្វើការទទួលស្គាល់ចំពោះសេចក្តីថ្លែងការរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងកាលពីថ្ងៃទី២៣ ខែវិច្ឆិកា ។ លោកស្រីបាននិយាយថា "ការប្រព្រឹត្តរបស់ជនត្រូវចោទមកលើជនរងគ្រោះ បានរំលឹកយើងទាំងអស់គ្នាពីផលប៉ះពាល់ដែលមិនចេះចប់មកលើជនរងគ្រោះ ។ វាប្រៀបបីដូចជាកាំបិតដែលបន្តផ្លាស់ប្តូរឆាកជីវិតរបស់ជនរងគ្រោះអស់មួយជីវិត ។ បេះដូងរបស់ជនរងគ្រោះទាំងនោះ កំពុងតែឈឺ ហើយនឹងមិនអាចព្យាបាលបានឡើយ" ។ លោកស្រីបន្តទៀតថា សហព្រះរាជអាជ្ញា មិនមានភាពភ្ញាក់ផ្អើល ដោយសារតែការស្នើសុំឲ្យមានគំនុំសងសឹក ឬអត់ឱនទោស និងបំភ្លេចនោះទេ ។ កិច្ចការរបស់ព្រះរាជអាជ្ញា គឺធ្វើយ៉ាងណាបង្ហាញថា រឿងក្តីនេះផ្តល់នូវភស្តុតាងដាក់បន្ទុកឲ្យលើសពីមន្ទិលសង្ស័យ និងស្នើឲ្យមានការអនុវត្តច្បាប់ប្រកបដោយយុត្តិធម៌ផ្អែកលើបទដ្ឋានយុត្តិធម៌អន្តរជាតិ ។

ដា លាង មានប្រសាសន៍ថា ជនរងគ្រោះត្រូវបានចាត់ទុកថាជាខ្មាំងរបស់ខ្មែរក្រហម ហើយដែលត្រូវបានគំរាមកំហែង បំភ័យ វាយដំ សម្លាប់ ជ្រមុជទឹក ស៊ីលាមកខ្លួនឯងទាំងបង្ខំ និងប្រឈមមុខនឹងភាពសាហាវព្រៃផ្សៃដែលមិនអាចរៀបរាប់បាន ។ ជនរងគ្រោះទាំងអស់បានប្រឈមមុខនឹងការស្លាប់ដោយមិនដឹងខ្លួននៅក្នុងស្បែអន្ធកាលរបស់វាលពិឃាតជើងឯក ដែលនេះគឺជាការស្លាប់ដោយភាពម៉ាក់ងាយប្រមាថនៅក្នុងដៃប្រជាជនកម្ពុជា ដែលសម្លាប់ប្រជាជនរួមជាតិជាមួយគ្នា ។ លោកស្រីបានកត់សម្គាល់ថា ជនរងគ្រោះរបស់មន្ទីរស-២១អាចមានចំនួនច្រើនដែលអាចធ្វើឲ្យអង្គសវនាការនេះ ត្រូវតែពង្រីកឲ្យធំដល់ទៅ ២៨ដងឯណោះ ។

ដា លាង មិនស្នើសុំអ្វីទាំងអស់ក្រៅពីការកាត់ទោសឲ្យជាប់ពន្ធនាគារដែលមានរយៈពេលយូរសម្រាប់ឌុច បើទោះបីជាជនត្រូវចោទបានបង្ហាញពីទំនួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្ម វិប្បដិសារី និងសេចក្តីគោរពចំពោះជនរងគ្រោះក៏ដោយ ។ បន្ថែមលើនេះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគ្មានអ្វីពាក់ព័ន្ធអ្វីនឹងលទ្ធិប្រជាធិបតេយ្យឡើយ ។ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យប្រជាជនកម្ពុជា ប្រមាណ ១.៧លាននាក់ត្រូវបានសម្លាប់រង្គាល ។ របបនេះ បានអនុវត្តមនោគមវិជ្ជាចម្លែកដែលពាក់ព័ន្ធនឹងអំពើ

ហិង្សាដ៏ព្រៃផ្សៃ ។ គោលដៅសម្រាប់អំពើហិង្សានេះ គឺសម្រាប់អ្នកមិនគោរពតាម ឬជនណាដែលមិនព្រមទទួលស្គាល់អំណាចគ្រប់គ្រងរបស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ ។

លោកស្រី បានពន្យល់ពាក្យ«កម្ទេច»ថា ជា«ការសម្លាប់ និងវាយបំផ្លាញ» ។ វាមានន័យថា ជាសកម្មភាពដែលធ្វើឲ្យជនរងគ្រោះបាត់បង់នូវលក្ខណៈជាមនុស្សដោយលក្ខណៈជាប្រព័ន្ធ ។ បើទោះបីជាអង្គជំនុំជម្រះសេចក្ដីប្រឆាំង ឌុច ផ្ដោតទៅលើតែគុកមួយគឺ មន្ទីរស-២១ក៏ដោយ ក៏គុកនេះមិនមែនជាគុកធម្មតាទេ ។ គុកទួលស្លែង គឺជាគុកនយោបាយគំរូនៅក្នុងទូទាំងប្រទេសកម្ពុជា ។

បក្សកុម្មុយនីស្តកម្ពុជាមានភាពជឿជាក់លើ ឌុច ក្នុងកិច្ចការវែកមុខជនក្បត់បដិវត្តន៍ ។ ជា លាង បានប្រាប់ចៅក្រមថា ឌុច ពិតជាគ្មានការចាប់អារម្មណ៍ចំពោះទុក្ខលំបាកវេទនារបស់ជនរងគ្រោះបន្តិចណាឡើយ ។ ឌុច គឺជាបេក្ខជនសាកសមបំផុតដែលអាចដំណើរការមន្ទីរស-២១បាន ។ លោកស្រី បាននិយាយថា «ឌុច តែងតែត្រូវបានរាប់អានដោយសមភាព និងសេចក្ដីគោរពពីសំណាក់ចៅក្រម ហើយ ឌុច ត្រូវបានមេធាវីការពារក្ដីដែលមានបទពិសោធន៍ធ្វើជាតំណាងឲ្យទៀតផង» ។

មានឧក្រិដ្ឋកម្មជាច្រើនមានលក្ខណៈធ្ងន់ធ្ងរហើយផ្ដល់ផលប៉ះពាល់ដល់ជនរងគ្រោះជាច្រើន ដែលសុទ្ធតែជាឧក្រិដ្ឋកម្មបំភ័យដល់សតិសម្បជញ្ញៈរបស់មនុស្ស ដែល ជា លាង បានរកឃើញដំណោះស្រាយសម្រាប់ឧក្រិដ្ឋកម្មទាំងនោះ ដោយការកាត់ទោសឲ្យជាប់ពន្ធធានាគារក្នុងរយៈពេលយូរ ។ វាមិនចោទជាបញ្ហាអ្វីទេ នៅពេលដែលជនត្រូវចោទផ្សេងទៀតមិនទទួលស្គាល់ទោស (ដែលគ្មានជនត្រូវចោទណាម្នាក់ក្នុងរឿងក្ដីលេខ០០២បានធ្វើ) ។ លោកស្រី បានស្នើសុំឲ្យមានការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ដែលអាចសន្មត់ថា ជាការកាត់ទោសឲ្យជាប់ពន្ធធានាគារអស់មួយជីវិត ។

## យុត្តាធិការ

ជា លាង បានរៀបរាប់ពីសមាសភាពសំខាន់របស់យុត្តាធិការលើជនដែលត្រូវទទួលការចោទប្រកាន់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ក្នុងន័យម្យ៉ាងទៀត គឺសំដៅលើ«មេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យ និងជនដែលមានទំនួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងទំនៀមទម្លាប់ រួមទាំងការ

រំលោភលើអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយកម្ពុជា» យោងតាមមាត្រាទី១ នៃច្បាប់របស់ អ.វ.ត.ក) ។ ក្នុងការគូសបញ្ជាក់ពីជនដែលជាប់ពាក់ព័ន្ធនឹងយុត្តាធិការនេះ លោកស្រី បាននិយាយថា រដ្ឋាភិបាលរបស់របបនេះ មិនមែនជាប្រភពនៃជនកាន់អំណាចពិតប្រាកដនោះទេ ។ អំណាចពិតប្រាកដ គឺស្ថិតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ឬ«បក្ស» ។ បក្សនេះ ត្រូវបានដឹកនាំដោយគណៈកម្មាធិការមជ្ឈិម និងនៅថ្នាក់បន្ទាប់គឺ គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលធ្វើសេចក្តីសម្រេចលើគោលនយោបាយរបស់របបនេះ ។ កម្លាំងដឹកនាំរបស់«អង្គការ» គឺបម្រើជាប្រយោជន៍ដល់វប្បធម៌នៃការលាក់ការណ៍សម្ងាត់ និងការគេចវេសពីទំនួលខុសត្រូវ ។

ដោយសារតែច្បាប់ អ.វ.ត.ក មិនបានផ្តល់នូវគោលការណ៍ណែនាំជាលាយល័ក្ខអក្សរទាក់ទិននឹងបញ្ហាមេដឹកនាំជាន់ខ្ពស់ សហព្រះរាជអាជ្ញាបានធ្វើការពិចារណាលើយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ។ ជា លាង បានពន្យល់ថា សហព្រះរាជអាជ្ញាចាំបាច់ត្រូវតែពិចារណាពីកម្រិតធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម វិសាលភាពទូទៅ វិសាលភាពដែនសមត្ថកិច្ច និងឥរិយាបថ ដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើង ។ លោកស្រីបាននិយាយថា ឧក្រិដ្ឋកម្មទាំងនោះមិនត្រូវបានកំណត់ត្រឹមតែមេដឹកនាំគោលនយោបាយប៉ុណ្ណោះទេ ។ ជាមួយគ្នានេះ មានអ្នកនៅក្រោមបង្គាប់មួយចំនួន ក៏បានជាប់នៅក្នុងសេចក្តីសម្រេចលើយុត្តាធិការរបស់តុលាការដែរ ។ សហព្រះរាជអាជ្ញាបានស្នើងយល់ថា ឌុច ជាជនជាប់នៅក្នុងយុត្តាធិការលើជនដែលត្រូវទទួលការចោទប្រកាន់ទាំងនៅក្នុងថ្នាក់ដឹកនាំ (សំដៅលើការគ្រប់គ្រងផ្ទាល់របស់ ឌុច នៅគុកទួលស្លែង) និងជាជនដែល«មានទំនួលខុសត្រូវខ្ពស់បំផុត» (ឌុច គឺជាអ្នកគ្រប់គ្រងជាអចិន្ត្រៃយ៍របស់មន្ទីរស-២១និងបានចូលរួមពាក់ព័ន្ធជាប្រចាំជាមួយនឹងគណៈកម្មាធិការមជ្ឈិម ដូច្នេះ ឌុច មានទំនួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មនៅមន្ទីរស-២១ក្នុងកម្រិតច្រើន) ។ ក្នុងករណីឧក្រិដ្ឋកម្ម«ធ្ងន់ធ្ងរ»នៅមន្ទីរស-២១ គឺស្ថិតនៅក្នុងចំណោមអំពើឃោរឃៅអាក្រក់បំផុត ។ មានមនុស្សលើសពី១២.០០០នាក់ត្រូវបានសម្លាប់នៅមន្ទីរស-២១នោះ ដូច្នេះចំនួនមនុស្សដ៏ច្រើននេះអាចចាត់ទុកថា មានទំហំស្មើនឹងឧក្រិដ្ឋកម្មកម្រិត«ធ្ងន់ធ្ងរ» ។

ជា លាង បានលើកឡើងពីសេចក្តីអះអាងរបស់មេធាវីការពារក្តីដែលថា ឌុច បានក្លាយជាជនរងកំហុសជំនួសអ្នកដទៃ ហើយដែលលោកស្រីបានជំទាស់ ។ មន្ទីរស-២១ គឺជាមន្ទីរសន្តិសុខជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យ ។ ឌុច មានទំនាក់ទំនងដាច់ដោយឡែកមួយជាមួយនឹងមេដឹកនាំរបស់របបនេះ ។ មន្ទីរស-២១ គឺជាមន្ទីរដែលមានលក្ខណៈប្លែក ពីព្រោះថា មន្ទីរនេះទទួលយកអ្នកទោស

មកពីគ្រប់ទិសទីទាំងអស់ក្នុងប្រទេស ។ ជាមួយគ្នានេះ មន្ទីរនេះមានលក្ខណៈប្លែក ដោយសារតែមន្ត្រីជាន់ខ្ពស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាល រួមទាំងចៅហ្វាយស្រុកផ្សេងៗទៀតដែលត្រូវបានបោសសម្អាត ក៏ត្រូវបានបញ្ជូនមកកាន់មន្ទីរស-២១នេះ ដើម្បីឃុំឃាំងនិងសម្លាប់ដែរ ។ ចម្លើយសារភាពនៅមន្ទីរស-២១ ទាំងអស់ត្រូវបានបញ្ជូនទៅឲ្យមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដូច្នេះ ថ្នាក់ដឹកនាំរបស់មន្ទីរស-២១នេះ ច្បាស់ជាបានចូលរួមណែនាំពីមេដឹកនាំទាំងនោះលើកិច្ចការសម្រេចថា តើនរណាត្រូវចាប់ខ្លួនជាបន្ទាប់ ។ គ្មានប្រធានគុកផ្សេងទៀតដែលមានឥទ្ធិពលលើការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាជាង ឌុច នោះទេ ។

## ចេតនាឧក្រិដ្ឋ

ជា លាង បានចាប់ផ្តើមលើកឡើងពីផ្នែកថ្មីមួយនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់របស់លោកស្រី ដោយធ្វើការពិចារណាពីចេតនាឧក្រិដ្ឋរបស់ ឌុច ។ លោកស្រីបាននិយាយថា ឌុច មិនបានយល់ព្រមទទួលស្គាល់ថា ខ្លួនបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយចេតនាឡើយ ។ ផ្ទុយទៅវិញ ឌុច បែរជាអះអាងថា ខ្លួនបានប្រព្រឹត្តឧក្រិដ្ឋកម្មតាមបញ្ជា និងការបង្ខិតបង្ខំ (ដោយភាពភ័យខ្លាចស្លាប់សម្រាប់ការមិនគោរពតាម) ។ លោកស្រីបន្តថា ការបដិសេធលើភាពចេតនារបស់ ឌុច នេះ មានបញ្ហាក់ក្នុងហេតុការណ៍ ដែលកើតមានឡើងជុំវិញឧក្រិដ្ឋកម្មទាំងនោះ ។

ជា លាង បានបង្កើតជាហេតុផលមួយដែលផ្អែកលើរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបប ប៉ុល ពត ថា ៖ តើហេតុការណ៍បញ្ជាក់ពីការពិតទាំងអស់នោះ អាចបកស្រាយទៅជាអ្វីផ្សេងបានដោយរបៀបណាក្រៅពីចេតនាឧក្រិដ្ឋរបស់ ឌុច ក្នុងការប្រព្រឹត្តឧក្រិដ្ឋដ៏សាហាវនេះ? លោកស្រីបានអះអាងថា ភាពព្រឺខ្លាចដ៏លើសលុបនៃហេតុការណ៍ទាំងនេះ ច្បាស់ជាកើតឡើងស្របពេលជាមួយនឹងចេតនាឧក្រិដ្ឋជាមិនខាន ។ លោកស្រីបានអធិប្បាយពីប្រទេសកម្ពុជាក្នុងលក្ខណៈឃោរឃៅថា ៖ បក្សកុម្មុយនីស្តកម្ពុជា បានចូលរួមក្នុងការសម្លាប់ជននយោបាយជាទ្រង់ទ្រាយថ្នាក់ជាតិ ។ មកដល់ឆ្នាំ១៩៧៦ ប្រទេសកម្ពុជាបានលុបបំបាត់ទ្រព្យសម្បត្តិឯកជន ចំណែកឯទីក្រុងទាំងអស់ត្រូវបានបោះបង់ចោល ។ បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមកម្ចាត់គ្នាឯង ។ គោលនយោបាយនេះ គឺធ្វើឡើងក្នុងគោលបំណង«កម្ទេច»ខ្មាំងខាងក្នុងនិងខាងក្រៅថ្នាក់ដឹកនាំរបស់បក្ស ។ មានការបោសសម្អាត

ឬវិសុទ្ធកម្ម បានកើតឡើងទូទាំងប្រទេស រួមទាំងសមាជិកគណៈកម្មាធិការមជ្ឈិមផងដែរ ។ មានមនុស្សរាប់ពាន់នាក់ត្រូវបានចាប់ខ្លួននិងសម្លាប់ ។

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ សុន សេន បានរៀបចំអង្គប្រជុំមួយដែលមាន ឌុច ជាអ្នកចូលរួម នេះគឺជាខណៈពេលដែលការបង្កើតមន្ទីរស-២១ត្រូវបានទទួលស្គាល់ពេញលេញ ។ មកដល់ខែវិច្ឆិកា ឆ្នាំ១៩៧៥ មន្ទីរស-២១បានចាប់ផ្តើមដំណើរការ ។ អ្នកទោសប្រមាណ១,៥០០នាក់ ត្រូវបានឃុំឃាំងជាលើកដំបូងនៅមន្ទីរស-២១ ដែលជាមជ្ឈមណ្ឌលសម្លាប់ និងធ្វើទារុណកម្មតាមលក្ខណៈជាប្រព័ន្ធ ។ មន្ទីរស-២១នេះ ត្រូវបានបង្កើតឡើងដើម្បីទាញយកចម្លើយសារភាពរបស់អ្នកទោសមុននឹងយកទៅសម្លាប់ ។ មានក្រុមអ្នកសួរចម្លើយបីក្រុមត្រូវបានបង្កើតឡើង ដើម្បីសម្រេចកិច្ចការនៅមន្ទីរស-២១នេះដូចជា ៖ ក្រុម«ត្រជាក់» ក្រុម«ក្តៅ» និងក្រុម«អង្កាម» ។ សហព្រះរាជអាជ្ញាបានស្វែងយល់ឃើញថា អ្នកយាមគុកមន្ទីរស-២១ ដែលនៅរស់រានមានជីវិតមិនមានចំណាប់អារម្មណ៍ក្នុងការនិយាយពីកិច្ចការរបស់គេនៅទីនោះឡើយ ប្រហែលជាដោយសារតែភាពភ័យខ្លាចថាត្រូវបានចាប់ខ្លួន ។ ប៉ុន្តែអ្នកយាមគុកទាំងនោះ គឺជាឧបករណ៍របស់កម្មាភិបាលជាន់ខ្ពស់ ហើយត្រូវបាន ឌុច និងគណៈកម្មាធិការមជ្ឈិមដាក់សម្ពាធនិងប្រើប្រាស់ ។ គោលបំណងនៃការ«កម្ទេច»ខ្មាំងត្រូវបានអនុវត្តជាបន្តបន្ទាប់នៅមន្ទីរស-២១ ដោយមានការឃោសនាតាមវិទ្យុរបស់បក្សកុម្មុយនីស្តកម្ពុជាយ៉ាងខ្ជូរខ្ជារគ្រប់ពេលទាំងអស់ ។

មន្ទីរស-២១ គឺជាកន្លែងដែលគ្មានជនណាម្នាក់អាចរត់គេចបានឡើយ ។ ក្នុងដំណើរការជំនុំជម្រះសេចក្តីចៅក្រមបានស្តាប់សក្ខីកម្មរបស់អ្នកទោសបីនាក់ ដែលបានរួចផុតពីសេចក្តីស្លាប់ដោយសារទេពកោសល្យរបស់គេ ។ បន្ថែមលើទុក្ខលំបាកវេទនាដែលអ្នកទោសទាំងនោះបានរៀបរាប់ ក៏មានការបូមយកឈាមទាំងបង្ខំ និងការវះកាត់ស្រស់ៗផងដែរ ។ ឈាមតែងតែត្រូវបានបូមជាញឹកញាប់ពីអ្នកទោសរហូតដល់ពួកគេដង្ហក់ដង្ហើមស្លាប់ នេះគឺដោយសារតែការបាត់បង់ឈាមរបស់អ្នកទាំងអស់នោះ ។ ជា លាង បានអះអាងចំពោះបញ្ហានេះទៅកាន់ ឌុច ថា ការអនុវត្តបូមឈាមចេញនេះ គ្មានន័យអ្វីទាំងអស់ ។ នៅក្នុងទឹកដក់ពណ៌ក្រហម ឌុច នឹងសរសេរបន្ថែមឈ្មោះជនរងគ្រោះបន្ទាប់ ដែលនេះហៅថា «ការកម្ទេចដោយឈាម» ។

លោកស្រីបានអះអាងថា ភាពសាហាវព្រៃផ្សៃរបស់ ឌុច ដែលធ្វើទៅលើអ្នកទោសច្បាស់ណាស់ថា គ្មានព្រំដែនកំណត់ទេ ។ អ្នកសួរចម្លើយមានសេរីភាពក្នុងការប្រើប្រាស់ការគិតរបស់គេដើម្បីធានាថា គ្មានការសម្លាប់កើតឡើងនៅក្នុងពេលធ្វើទារុណកម្មឡើយ ។ អ្នកទោសដែលមានបុណ្យស័ក្តិខ្ពស់ត្រូវបាន គម្រាមថា ប្រសិនបើគេមិនព្រមសារភាពទេនោះ ទីកន្លែងរស់នៅរបស់សមាជិកគ្រួសារនឹងត្រូវស៊ើប រក ហើយក៏ត្រូវធ្វើការចាប់ខ្លួនបន្ទាប់មកទៀត ។

ការចាប់ខ្លួនមនុស្សម្នាក់បានផ្តន្ទាទោសរបស់គេរួចជាស្រេចទៅហើយ មុននឹងការមកដល់មន្ទីរស-២១ របស់គេ ។ ដោយសារតែគ្មានការចាប់ខ្លួនដោយខុសច្បាប់ត្រូវបានធ្វើឡើង នោះការកម្ចាត់ខ្មាំងចោល គឺជាកិច្ចការបន្ទាប់របស់មន្ទីរស-២១ ។ នៅមន្ទីរស-២១ សម្លេងស្រែកថ្ងូររបស់ជនរងគ្រោះ និងក្លិន សាកសពស្អុយរលួយ តែងតែកើតឡើងជាប្រចាំតាំងពីព្រឹកព្រលឹមជារៀងរាល់ថ្ងៃ ។ ការសម្លាប់ គឺ ប្រាកដជាកើតឡើងចំពោះអ្នកទោសគ្រប់រូប ។ អ្នកទោសម្នាក់ៗបានគិតទុកពីការស្លាប់របស់គេជាង ១.០០០ដងក្នុងអំឡុងពេលទទួលទារុណកម្មនិងឃុំឃាំងរបស់គេ ។ នៅចំពោះមុខតុលាការសាក្សីពីរនាក់ ដែលបាននៅរស់រានមានជីវិតពីរាលពិឃាតដើងឯក បានរៀបរាប់ពីដោគវាសនារបស់ជនរងគ្រោះ ។ ប៉ុន្តែ គ្មាននរណាម្នាក់អាចពន្យល់ឲ្យបានក្បោះក្បាយពីភាពភ័យខ្លាច និងទុក្ខលំបាកវេទនារបស់ជនរង គ្រោះ ជាងអ្វីដែលពួកគេបានដឹងព្រោះដោយសារតែអ្នកទោសទាំងអស់នេះ បានគិតទុកថាពួកគេនឹងត្រូវ សម្លាប់ចោល ។ សាកសពទាំងអស់ត្រូវបានត្រួតពិនិត្យក្រែងមានអ្នកទោសខ្លះនៅមានជីវិត ។ មុននឹង កប់សាកសពទាំងអស់នេះត្រូវបានវះបំពង់ក និងពោះដោយកាំបិត ។ មានតែ ឌុច ម្នាក់គត់ដែល ជាមន្ត្រីគុកមានអំណាចក្នុងការរាយការណ៍ព័ត៌មានទាំងអស់នេះទៅកាន់មេដឹកនាំជាន់ខ្ពស់ ។

## ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ជា លាង បានបន្តរៀបរាប់ពីឧក្រិដ្ឋកម្មដែលត្រូវបានបញ្ជាក់ដោយហេតុការណ៍ទាំងនេះ ដូចសេចក្តី សង្ខេបនៃសេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សររបស់សហព្រះរាជអាជ្ញា ។ ប្រភេទឧក្រិដ្ឋកម្មដំបូងដែល លោកស្រីបានរៀបរាប់ គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ សហព្រះរាជអាជ្ញាបានអះអាងថា ឧក្រិដ្ឋ កម្មចំនួន៧ ក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំង៩ ដូចដែលមានចែងនៅក្នុងមាត្រាទី៥ នៃ ច្បាប់របស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ ។ លក្ខខណ្ឌវិសាលភាពនៃឧក្រិដ្ឋកម្មទាំងនេះ គឺថា ការប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ត្រូវតែក្លាយជាផ្នែកមួយនៃការវាយប្រហាររាលដាល

និងជាលក្ខណៈប្រព័ន្ធលើប្រជាជនស៊ីវិល ។ ជាក់ស្តែង ឧក្រិដ្ឋកម្មនៅមន្ទីរស-២១ បានចូលរួមចំណែកក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានលក្ខណៈទ្រង់ទ្រាយធំនៅទូទាំងប្រទេសកម្ពុជា ។ លោកស្រីបាននិយាយថា ទោះបីជាឧក្រិដ្ឋកម្មនោះបានចាត់ទុកថាកើតឡើងដាច់ដោយឡែកតែឯងក៏ដោយ ក៏ឧក្រិដ្ឋកម្មដែលកើតឡើងនៅមន្ទីរស-២១នោះបានរាលដាលយ៉ាងខ្លាំងក្លា ។ ជនរងគ្រោះមកពីគ្រប់ទិសទីទាំងអស់ក្នុងប្រទេសកម្ពុជា បានប្រឈមមុខនឹងការធ្វើទារុណកម្ម និងការសម្លាប់នៅក្នុងគុកនេះ ។ ជនរងគ្រោះដែលមានចំនួនលើសពី១២.២០០នាក់ បានបញ្ជាក់នៅក្នុងការសាកល្បងថា ឧក្រិដ្ឋកម្មទាំងនោះពិតជាមានលក្ខណៈ«រាលដាល» ។

អ្វីៗដែលបានកើតឡើងនៅមន្ទីរស-២១ ក៏ត្រូវតែចាត់ទុកថាជាឧក្រិដ្ឋកម្មដែលមានលក្ខណៈ«ជាប្រព័ន្ធ» ហើយបានរៀបចំ និងសម្របសម្រួលដោយបក្ស ។ វាមានន័យថា អ្នកបន្ទាប់បញ្ជារបស់បក្ស បានអនុវត្តឧក្រិដ្ឋកម្មទាំងនេះដោយមានរបៀបនិងប្រុងប្រយ័ត្ន ។ ការវាយប្រហារលើមនុស្សប្រមាណពីដប់ពាន់ទៅមួយរយពាន់នាក់នៅមន្ទីរស-២១នេះ បានចែងនៅក្នុងមាត្រាទី៥ ស្តីពីការវាយប្រហារ ។ គោលដៅនៃការវាយប្រហារនេះ គឺសំដៅលើជនស៊ីវិលសំខាន់ជាច្រើននៅមន្ទីរស-២១ ។

និយមន័យសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងមាត្រាទី៥នៃច្បាប់ អ.វ.ត.ក បានបន្ថែមសេចក្តីតម្រូវមួយទៀតថា : ក្នុងចំណោមឧក្រិដ្ឋកម្មផ្សេងទៀត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ បានប្រព្រឹត្តឡើងសំដៅលើផ្នែកនយោបាយ សាសនា និងជាតិពន្ធុ ។ តាមពិត ការវាយប្រហារដែលកើតមានឡើងនៅមន្ទីរស-២១ ត្រូវបានអនុវត្តដោយសារតែលទ្ធផលនៃមនោគមវិជ្ជានយោបាយ និងការសម្លាប់ជននយោបាយ ។ ការវាយប្រហារទាំងនោះ រួមមានការរើសអើងជាតិពន្ធុលើអ្នកទោសជនជាតិវៀតណាម ។ គ្មានសាសនាណាមួយបានទទួលនូវការអាធ្យាស្រ័យឡើយ សូម្បីតែសាសនាព្រះពុទ្ធ រួមទាំងសាសនាអ៊ីស្លាម និងគ្រិស្តផងដែរ ។ ជនដៃដល់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ច្បាស់ជាមានការយល់ដឹងពីការវាយប្រហារលើប្រជាជនស៊ីវិលទាំងនេះ ។ ឌុច បានដឹងថាឧក្រិដ្ឋកម្មដែលកើតមានឡើងនៅមន្ទីរស-២១ គឺជាផ្នែកមួយនៃការវាយប្រហារលើប្រជាជនស៊ីវិល ។ ឌុច តែងតែមានទំនាក់ទំនងជាប់ជាប្រចាំជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ ការជួបប្រជុំជាមួយនឹងមេដឹកនាំបក្សទាំងនោះបានប្រាប់ឲ្យ ឌុច ដឹងពីស្ថានភាពទីកន្លែងផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ។ តាមរយៈការអានកំណត់ហេតុសួរចម្លើយយ៉ាងច្រើននៅមន្ទីរស-២១ ឌុច បានយល់ដឹងយ៉ាងច្បាស់ពីបរិបទនៃការវាយប្រហារលើប្រជាជនស៊ីវិល ។

បន្ទាប់មកទៀត ដា លាង បានពិចារណាពីបទល្មើសទី៧ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកផ្សេងទៀតដែលកើតឡើងនៅមន្ទីរស-២១ មានដូចជា ៖ ការដាក់ឃុំឃាំង សកម្មភាពអមនុស្សធម៌ផ្សេងទៀត ការដាក់ជាទាសករ ការរំលោភ ការធ្វើទារុណកម្ម ការសម្លាប់ ការសម្លាប់បំផុតពូជ និងការធ្វើបុកទុក្ខម្នេញលើអ្នកនយោបាយ អ្នកកាន់សាសនា និងជនជាតិផ្សេង ។ លោកស្រីបាននិយាយថា សាកសពអ្នកទោសចំនួន១២.២៧៣នាក់នៅមន្ទីរស-២១ ត្រូវបានចងក្រងចេញពីឯកសារកត់ត្រាឈ្មោះអ្នកទោស ប៉ុន្តែអ្នកទោសជាច្រើនដែលបានមកដល់មន្ទីរស-២១ហើយស្លាប់ភ្លាមៗមិនត្រូវបានកត់ត្រាទុកឡើយ ដូច្នេះចំនួនសាកសពមនុស្សស្លាប់នៅទីនោះអាចចាត់ទុកថា មានចំនួនច្រើនជាងនេះ ។ គ្មានការកំណត់ជាមូលដ្ឋានច្បាប់ត្រឹមត្រូវសម្រាប់ការចាប់ខ្លួននៅក្នុងរបបនេះឡើយ ដូច្នេះវាមានន័យថាគ្មានប្រព័ន្ធច្បាប់ណាមួយបានបង្កើតឡើង ដើម្បីគ្រប់គ្រងដំណើរការរបស់មន្ទីរនេះទេ ។ សកម្មភាពដ៏សាហាវជាច្រើនដែលកើតមានឡើងនៅមន្ទីរស-២១ បានបង្កើតឲ្យមានជាប្រភេទ«សកម្មភាពអមនុស្សធម៌ផ្សេងទៀត»ដោយងាយស្រួលបំផុត ។ ឌុច បានចេញបញ្ជាដោយផ្ទាល់ឲ្យទៅបំភ័យអ្នកទោស និងធ្វើយ៉ាងណាឲ្យសកម្មភាពសាហាវទាំងនោះទទួលបានលទ្ធផលសម្រេច ។ ស្ថានភាពនៅមន្ទីរស-២១បានក្លាយជាទីកន្លែងសម្រាប់ដាក់មនុស្សជាទាសករ ដោយសារតែមហិច្ឆិតាអនុវត្តភាពជាម្ចាស់ការ និងការគ្រប់គ្រងលើអ្នកទោសរបស់ ឌុច ។ ឌុច ត្រូវតែទទួលខុសត្រូវសម្រាប់ទំនួលខុសត្រូវក្នុងនាមជាថ្នាក់ដឹកនាំចំពោះសកម្មភាពរំលោភដែលកើតមានឡើងនៅក្នុងគុកនេះ ។ ការធ្វើទារុណកម្ម គឺពិតជាផ្នែកមួយនៃវប្បធម៌របស់មន្ទីរស-២១ ដែលពិតជាមានលក្ខណៈជាប្រព័ន្ធ ។ ការធ្វើទារុណកម្ម គឺជាឧបករណ៍គ្រប់គ្រងការសួរចម្លើយ និងទាញយកចម្លើយសារភាពពីអ្នកទោស ។ ដា លាង បានអះអាងថា ឌុច បានធ្វើទុក្ខទោសម្នេញលើអ្នកទោសដោយផ្ទាល់ ។ ការសម្លាប់អ្នកទោសជាលក្ខណៈទ្រង់ទ្រាយធំបែបនេះបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិសម្រាប់ការសម្លាប់បែបនោះ ។ ជនទាំងអស់ដែលជួបឃុំខ្លួននៅទីនោះត្រូវតែសម្លាប់ចោល ។ ចៅក្រមបានស្តាប់ពុស្សក្ខីកម្មជាច្រើនដែលរៀបរាប់ពីរឿងរ៉ាវទាំងនេះ ។ ការស្លាប់បានកើតមានឡើងជាទ្រង់ទ្រាយធំដែលជាហេតុបង្កជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិសម្រាប់ការសម្លាប់បំផុតពូជ ។ ការរើសអើងបានកើតឡើងចំពោះជននយោបាយ អ្នកកាន់សាសនា និងជនជាតិផ្សេងទៀត ។

## ឧក្រិដ្ឋកម្មសង្គ្រាម

បន្ទាប់មកទៀត ជា លាង បានបង្វែរចំណាប់អារម្មណ៍របស់លោកស្រីមកផ្តោតលើបទចោទប្រកាន់ចំពោះ ឌុច ទៅលើឧក្រិដ្ឋកម្មសង្គ្រាម ។ សំណួរបានចោទសួរថា ៖ តើហេតុអ្វីបានជាការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើ ឌុច នៅមិនគ្រប់គ្រាន់? លោកស្រីបានឆ្លើយតបនឹងសំណួរនេះដោយនិយាយថា នីតិវិធីបានចែងថា សហព្រះរាជអាជ្ញាត្រូវអនុវត្តច្បាប់ ហើយនីតិវិធីនេះក៏មានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ យោងតាមមាត្រាទី៦ នៃច្បាប់ អ.វ.ត.ក ។ លោកស្រីបាននិយាយថា វាពិតជាមានសារសំខាន់ក្នុងការសម្រេចឲ្យបានថា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវតែទទួលទណ្ឌកម្ម ពីព្រោះការធ្វើដូច្នេះ អាចនឹងធានាឲ្យមានឥទ្ធិពលទប់ស្កាត់កុំឲ្យមានជម្លោះប្រដាប់អាវុធនាពេលអនាគត់ ។ ប្រសិនបើគ្មានការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាមទេ នោះប្រាកដជាគ្មានការរៀបរាប់ពីរឿងរ៉ាវទាំងអស់ទាក់ទិននឹង ឌុច ជាពិសេសគឺទំនាក់ទំនងរបស់ ឌុច ជាមួយនឹងជនជាតិវៀតណាមស្លូតត្រង់ដែលបាននាំមកកាន់មន្ទីរស-២១ ។

ជា លាង បានគូសបញ្ជាក់ថា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំនួន៧ក្នុងចំណោមការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំនួន៩ដែលមានចែងនៅក្នុងមាត្រាទី៦ នៃច្បាប់ អ.វ.ត.ក បានកើតមានឡើងនៅមន្ទីរស-២១ មានជាអាទិ៍ដូចជា ៖ ការឃុំឃាំងខុសច្បាប់ ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម និងប្រជាជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ ការបង្កឲ្យមានការឈឺចាប់ ការធ្វើទារុណកម្ម ឬការប្រព្រឹត្តអមនុស្សធម៌ និងការសម្លាប់ដោយចេតនា ។ លោកស្រីបាននិយាយថា វាពិតជាមានលក្ខណៈលើសពីមន្ទិលសង្ស័យដែលថាជម្លោះប្រដាប់អាវុធអន្តរជាតិបានចាប់ផ្តើមនៅខែមេសា ឆ្នាំ១៩៧៥ និងបានបញ្ចប់នៅខែមករាឆ្នាំ១៩៧៩ ។ ឌុច បានដឹងយ៉ាងច្បាស់ពីស្ថានភាពជម្លោះប្រដាប់អាវុធអន្តរជាតិ យ៉ាងហោចណាស់មុនពេលដែលកងទ័ពវៀតណាមបានមកដល់មន្ទីរស-២១ជាឡើងដំបូង ។ ជាក់ស្តែង ឌុច បានចងក្រងជាឯកសារសរសេរដោយដៃផ្ទាល់សម្រាប់ការមកដល់របស់កងទ័ពវៀតណាម ដែលកងទ័ពទាំងអស់នេះនឹងត្រូវទទួលបានការការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ ។ កងទ័ពវៀតណាមទាំងនោះ ត្រូវតែទទួលបានឋានៈជាអ្នកទោសសង្គ្រាមយោងតាមអនុសញ្ញាទីក្រុងហ្សឺណែវ ។ ចំណែកឯ ឌុច ក៏បានដឹងច្បាស់ថា កងទ័ពវៀតណាមទាំងនោះទទួលបានឋានៈការពារខ្លួនទាំងកងទ័ពវៀតណាម ដែលចាប់ខ្លួននៅក្នុងសមរភូមិ និងប្រជាជនស៊ីវិលវៀតណាមដែលចាប់ខ្លួននៅទឹកដីរបស់វៀតណាមក្នុងអំឡុងពេលសង្គ្រាម ។

ជា លាង បានសង្កត់ធ្ងន់ថា ជនជាតិវៀតណាមបានទទួលរងទុក្ខវេទនាមិនខុសគ្នា ប៉ុន្មានពីប្រជាជនកម្ពុជានៅមន្ទីរស-២១ឡើយ វាមានន័យថាចេតនាឧក្រិដ្ឋរបស់ ឌុច ដែលធ្វើចំពោះជនជាតិកម្ពុជា

មិនខុសគ្នាលើអ្នកទោសជនជាតិវៀតណាមទាំងនោះឡើយ ។ លោកស្រីបានចាត់ទុកធាតុផ្សំនៃការធ្វើទារុណកម្មថាជាឧក្រិដ្ឋកម្មសង្គ្រាម ដែលមានលក្ខណៈដូចគ្នាសុទ្ធសាធនឹងការធ្វើទារុណកម្មសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ បើទោះបីជាលោកស្រី បានទទួលស្គាល់ថាសហព្រះរាជអាជ្ញាមិនមានភស្តុតាងជាក់លាក់ណាមួយបង្ហាញពីការធ្វើទារុណកម្មលើអ្នកទោសជនជាតិវៀតណាមក៏ដោយ ក៏លោកស្រីជឿថា ការធ្វើទារុណកម្មបែបនោះអាចនឹងចាត់ទុកថាជាការប្រើប្រាស់រួមមួយសម្រាប់មន្ទីរស-២១ ។

ជា លាង បានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ដោយរៀបរាប់ពីការអនុវត្តមាត្រាទី៣ថ្មី នៃច្បាប់ អ.វ.ត.ក ដែលដាក់បញ្ចូលឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ទៅក្នុងយុត្តាធិការរបស់តុលាការ ។ លោកស្រីបាននិយាយថា ការដាក់បញ្ចូលឧក្រិដ្ឋកម្មទាំងនេះចូលក្នុងយុត្តាធិការរបស់តុលាការ ពិតជាមានសារសំខាន់សម្រាប់ការអនុវត្តច្បាប់របស់តុលាការ ។ «នេះគឺជាតុលាការសម្រាប់ប្រជាជនកម្ពុជា ដូច្នេះវាពិតជាមានសារសំខាន់ក្នុងការធ្វើឲ្យច្បាប់កម្ពុជាត្រូវបានប្រតិបត្តិ និងប្រើប្រាស់ត្រឹមត្រូវដើម្បីការពារប្រជាជនកម្ពុជាគ្រប់រូប» ។ តាមទស្សនៈរបស់លោកស្រី ក្រមព្រហ្មទណ្ឌបានកំណត់យ៉ាងច្បាស់ពីសកម្មភាពរបស់ ឌុច ថាជាឧក្រិដ្ឋកម្មសម្រាប់ការសម្លាប់ និងធ្វើទារុណកម្ម ។ លោកស្រីបានចាត់ទុកភាពសាហាវយង់ឃ្នងដែលបានកើតឡើងនៅក្នុងគុកថាត្រូវបានការពារដោយឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម ។

## សហព្រះរាជអាជ្ញាអន្តរជាតិ វីលៀម ស្មីត

វីលៀម ស្មីត សហព្រះរាជអាជ្ញាអន្តរជាតិ បានក្រោកធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលដោយគូសបញ្ជាក់ពីទោសរបស់ ឌុច សម្រាប់ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ។ លោកបានចាប់ផ្តើមដោយសួរពីយុត្តិធម៌ក្នុងនោះសំណួរទាំងអស់នោះគឺ : តើអ្វីទៅជាយុត្តិធម៌សម្រាប់មនុស្សចំនួន ១២.២០០នាក់ ដែលត្រូវបានសម្លាប់យ៉ាងសាហាវនៅមន្ទីរស-២១? តើអ្វីទៅជាយុត្តិធម៌សម្រាប់សមាជិកគ្រួសារនិងមិត្តភិក្តិរបស់ជនរងគ្រោះ? សេចក្តីសម្រេចរបស់ចៅក្រមនឹងមិននាំយកជនរងគ្រោះទាំងនោះត្រឡប់មកវិញឡើយ ។ ជនរងគ្រោះនឹងមិនបានឃើញកូនចៅរបស់ខ្លួនរត់លេងសប្បាយ ។ អ្នកដែលបានបាត់បង់ជីវិតទាំងនោះ នឹងមិនបានរីតចំណងស្នេហារបស់គេ ។ ហើយឪពុកម្តាយដែលស្លាប់ហើយនោះ នឹងមិនអាចមានមោទនៈភាពចំពោះអ្វីដែលពួកគេបានបន្សល់ទុកឡើយ ។ កិច្ចការរបស់សហ

ព្រះរាជអាជ្ញា គឺសម្រេចឲ្យបាននូវយុត្តិធម៌ ហើយយុត្តិធម៌នឹងត្រូវបានសម្រេចឲ្យមានតាមរយៈការអនុវត្តច្បាប់របស់ អ.វ.ត.ក ដោយរៀបចំឲ្យមានការជំនុំជម្រះសេចក្តីប្រកបដោយយុត្តិធម៌ និងផ្តល់ភស្តុតាងដាក់បន្ទុកឲ្យលើសពីមន្ទិលសង្ស័យ ។ ការផ្តន្ទាទោសត្រូវតែសម្រេចឲ្យស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ គោលដៅរបស់តុលាការនេះ គឺការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់ និងការទប់ស្កាត់កុំឲ្យឧក្រិដ្ឋកម្មកើតឡើងម្តងទៀត ។ ប្រជាជនកម្ពុជាពិតជាសមនឹងទទួលបានការការពារខ្លួន ហើយជីវិតរបស់ប្រជាជនទាំងនេះ គឺពិតជាសមនឹងទទួលការគោរព ។ វីលៀម ស្មីត បានថ្លែងថា “មន្ទីរស-២១ មិនគួរត្រូវបានកើតឡើងឡើយ ហើយវាក៏នឹងមិនត្រូវកើតឡើងម្តងទៀតដែរ” ។ ដូច្នេះតើអ្វីទៅជាយុត្តិធម៌? វីលៀម ស្មីត បាននិយាយថា យុត្តិធម៌អាចនឹងសម្រេចបានតាមរយៈកត្តាធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ឥទ្ធិពលឧក្រិដ្ឋកម្មលើជនរងគ្រោះ និងតួនាទីរបស់ ឌុច ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ ឌុច បានអះអាងក្នុងអំឡុងដំណើរការជំនុំជម្រះសេចក្តីថា ឧក្រិដ្ឋកម្មនៅមន្ទីរស-២១ បានកើតឡើងផ្ទុយពីឆន្ទៈរបស់ខ្លួន នោះគឺដោយសារតែភាពភ័យខ្លាចស្លាប់ និងការគ្មានឱកាសរត់គេចខ្លួន ។ ឌុច បានចាត់ទុកខ្លួនឯងថាជាជនរងគ្រោះម្នាក់នៃប្រព័ន្ធគ្រប់គ្រងបក្សនេះ ។ សម្រាប់ វីលៀម ស្មីត វិញ មិនបានចាត់ទុក ឌុច ថាជាអ្នកទោសចំណាប់ខ្មាំង ឬជាជនរងគ្រោះឡើយ ។ ផ្ទុយទៅវិញ ឌុច គឺជាឧត្តមគតិបុគ្គលដែលជាជនស្នេហាបដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជា និងជាអ្នកបូជាអ្វីៗគ្រប់យ៉ាងជូនបក្ស ។ លោកបានអះអាងថា នេះគឺជាភាពខុសប្លែកគ្នាយ៉ាងសំខាន់រវាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីក្នុងការចាត់ទុក ឌុច ថាជាបុគ្គលបែបណា ។

វីលៀម ស្មីត បានបន្តអះអាងថា វាមិនមែនជារឿងចៃដន្យទេដែល ឌុច មានគ្រួសារដ៏សុខសប្បាយមួយក្នុងអំឡុងរបបខ្មែរក្រហម ។ ឌុច បានកាន់តំណែងខ្ពស់មួយ ។ ឌុច បានផ្លាស់មកធ្វើជាប្រធានមន្ទីរស-២១ ដោយស្មារតីខិតខំប្រឹងប្រែងធ្វើការងារ និងយកចិត្តទុកដាក់យ៉ាងល្អិតល្អន់ ។ ឌុច មានបំណងចង់កម្ចាត់ខ្មាំងរបស់បក្ស ។ ឌុច មានទំនាក់ទំនងផ្ទាល់ជាមួយនឹងមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច នៅតែបន្តសហការជាមួយនឹងមេដឹកនាំទាំងនោះអស់រយៈពេល១៥ឆ្នាំក្រោយពីរបប កម្ពុជាប្រជាធិបតេយ្យបានដួលរំលំទៅ ។ បន្ថែមលើនេះ ឌុច គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សពីរនាក់ដែលបានចូលជួបជាមួយនឹង សុន សេន កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ ដើម្បីបង្កើតមន្ទីរស-២១ ។ លេខ២១ សម្រាប់មន្ទីរស-២១នេះ ត្រូវបានជ្រើសរើសដោយហេតុផលផ្ទាល់ខ្លួនរបស់ ឌុច ។ ឌុច បានជ្រើសរើសមនុស្សដែលខ្លួនទុកចិត្តដោយខ្លួនឯងមកធ្វើជាអ្នកសួរចម្លើយ និងអ្នកធ្វើទារុណកម្ម ។

ឌុច ចង់គ្រប់គ្រងមន្ទីរស-២១ដោយខ្លួនឯង ប៉ុន្តែមិនចង់ធ្វើកិច្ចការកខ្វក់នេះដោយខ្លួនឯងទេ ។ ឌុច បានបង្រៀនវិធីសាស្ត្រសួរចម្លើយ តាមដានខ្លាំង និងបញ្ជាឲ្យធ្វើទារុណកម្មអ្នកទោស ។

វីលៀម ស្មីត បានគូសបញ្ជាក់ថា ឌុច បានបង្កើតជារោគភ័យខ្លាចនៃរបបនេះតាមរយៈរបាយការណ៍សួរចម្លើយរបស់ខ្លួន ។ ទំនាក់ទំនងដ៏ជិតស្និទ្ធរបស់ ឌុច ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ទាំងនោះ ពិតជាសាកសមនឹង ឌុច ណាស់ ។ ឌុច តែងតែនិយាយពីមេដឹកនាំទាំងនោះដើម្បីកោតសរសើរ និងធ្វើឲ្យមេដឹកនាំទាំងនោះពេញចិត្តនឹងកិច្ចការរបស់ខ្លួន ។ ក្នុងអំឡុងដំណើរការជំនុំជម្រះសេចក្តី ឌុច តែងតែនិយាយពី សុន សេន ដោយកោតសរសើរ ។ ឌុច បានចាត់ទុក សុន សេន ជាជនដែលមានឥទ្ធិពលធំជាងគេបំផុតរបស់ខ្លួន ។ ប៉ុន្តែនៅពេលដែល នួន ជា បានឡើងធ្វើការគ្រប់គ្រងជំនួស សុន សេន មក ឌុច នៅតែកាន់កាប់មុខតំណែងរបស់ខ្លួននៅមន្ទីរស-២១ដដែល និងបានបន្តរាយការណ៍ជូន នួន ជា ។

វិសាលភាពនៃអំណាចរបស់ ឌុច នៅមន្ទីរស-២១ ពិតជាមានលក្ខណៈធំធេង ។ ឌុច គឺជាមនុស្សល្អិតល្អន់ មានហេតុផល និងជ្រុលនិយម ។ ឌុច មានការចង់ចាំដ៏អាស្ចារ្យសម្រាប់តែហេតុការណ៍មួយចំនួនតែប៉ុណ្ណោះ ។ នៅក្នុងការគ្រប់គ្រងរបស់ ឌុច នៅមន្ទីរស-២១ វិន័យត្រូវតែគោរពតាម ហើយបញ្ជាត្រូវតែអនុវត្តឲ្យបានគ្រប់ពេលវេលាទាំងអស់ ។ ឌុច បានជ្រើសរើស និងបំពាក់បំប៉នបុគ្គលិកចំនួន ២០០០នាក់ដោយខ្លួនឯង ។ ឌុច បានប្រតិបត្តិវិន័យដោយគ្មានមេត្តា និងបានធ្វើឲ្យបុគ្គលិករបស់ខ្លួនមានភាពភ័យខ្លាចឥតឈប់ឈរ ។ អ្នកទោសចំនួន១៥៥នាក់ដែលត្រូវបានសម្លាប់ គឺសុទ្ធតែជាអតីតបុគ្គលិកមន្ទីរស-២១ ហើយ ឌុច គឺជាអ្នកផ្តើមគំនិត និងបញ្ជាឲ្យមានការសម្លាប់បុគ្គលិកទាំងនោះ ។ ឌុច បានសម្រេចមិនប្រើប្រាស់ប្រភេទទណ្ឌកម្មដែលមានលក្ខណៈស្រាលចំពោះបុគ្គលិកទាំងនោះឡើយ ។ តួនាទីសំខាន់របស់ ឌុច គឺធ្វើយ៉ាងណាធានាឲ្យបានថា មនោគមវិជ្ជានយោបាយរបស់បក្សកុម្មុយនីស្តត្រូវបានប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ ។ ក្នុងនាមជាគ្រូបង្រៀនដ៏មានទេពកោសល្យជាអ្នកសួរចម្លើយដ៏មានជំនាញ និងជាអ្នកជឿជាក់ខ្លាំងលើគោលនយោបាយបក្ស ឌុច ពិតជាសាកសមនឹងតួនាទីដែល ឌុច បានបំពេញនៅមន្ទីរស-២១ណាស់ ។

វីលៀម ស្មីត បានរៀបរាប់ពីតួនាទីរបស់ ឌុច ក្នុងវគ្គបំពាក់បំប៉ននៅមន្ទីរស-២១ និងបានសង្កត់ធ្ងន់ពីការយល់ដឹងរបស់ ឌុច ថា អំពើអមនុស្សធម៌ គឺជើរតួយ៉ាងសំខាន់នៅក្នុងវគ្គបំពាក់បំប៉នបុគ្គលិក ។ ឌុច គឺជាអ្នកចាត់ការដ៏ពូកែម្នាក់របស់មជ្ឈមណ្ឌលធ្វើទារុណកម្មនៅមន្ទីរស-២១នេះ ។ ឌុច បានបំពេញ

តួនាទីដោយផ្ទាល់យ៉ាងល្អិតល្អន់ទាក់ទិននឹងទិដ្ឋភាពការងារគ្រប់សព្វ ។ ជាក់ស្តែង ប្រសិនបើ ឌុច មិនធ្វើដូច្នេះទេនោះ ឌុច ប្រហែលជាមិនអាចធ្វើឲ្យមន្ទីរស-២១ មានដំណើរការទៅមុខប្រកបដោយប្រសិទ្ធភាពបែបនេះទេ ។ នៅមន្ទីរស-២១ ឌុច គឺជាអ្នកចេញរាល់សេចក្តីសម្រេចទាំងអស់ ។

វីលៀម ស្មីត បានបន្តរៀបរាប់ពីការចូលរួមរបស់ ឌុច នៅក្នុងសកម្មភាពសំខាន់ៗរបស់មន្ទីរស-២១ ។ ឌុច គឺជាអ្នកស៊ើបអង្កេតតាមដានដ៏សកម្មម្នាក់ ។ ឌុចបានចូលរួមបំពេញតួនាទីយ៉ាងសកម្មក្នុងកិច្ចការចាប់ខ្លួនមនុស្សយកមកមន្ទីរស-២១ ។ ឌុច គឺជាអ្នកផ្តើមគំនិតឲ្យមានការចាប់ខ្លួនមនុស្សរាប់រយនាក់ ប្រសិនបើមិនមែនរាប់ពាន់នាក់ ។ ឌុច បានបង្កើតឲ្យមានទ្រឹស្តី“ខ្សែក្បាត់”ដែលបង្កឲ្យមានការសួរចម្លើយដោយធ្វើទារុណកម្មដែលមានការចាប់ខ្លួនថ្មីដ៏ច្រើនបន្ថែមទៀត ។ ការចាប់ខ្លួនតែងតែធ្វើឡើងដោយវិធីសាស្ត្របោកប្រាស់ ដើម្បីបញ្ឆោតនាំយកមនុស្សទាំងនោះមកកាន់មន្ទីរស-២១ ។ ឌុច បានចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើវិសុទ្ធកម្មដែលមានទ្រង់ទ្រាយធំរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច គឺជាមនុស្សតែមួយគត់ដែលបញ្ជាក់ពីពេលដែលការសួរចម្លើយបានបញ្ចប់ពេញលេញ ហើយជាពិសេស ឌុច បានរីករាយជាមួយនឹងការសួរចម្លើយអ្នកទោសដែលមានឋានៈខ្ពស់ ។

យ៉ាងណាមិញ វីលៀម ស្មីត បាននិយាយថា ឌុច មិនអាចបំពេញតម្រូវការសំខាន់បំផុតមួយរបស់មនុស្សជាតិបានទេ តម្រូវការនោះ គឺការធ្វើឲ្យភាពឈឺចាប់មានភាពធូរស្បើយ ។ ឥរិយាបថរបស់ ឌុច មានលក្ខណៈម៉ឺងម៉ាត់និងដាច់ការ ជាហេតុធ្វើឲ្យ ឌុច គ្មានអារម្មណ៍ត្រេកអរនឹងទទួលយកមិត្តភក្តិ និងអ្នកសហការជិតស្និទ្ធណាម្នាក់ឡើយ ។ ជាក់ស្តែង មិត្តភក្តិពីរនាក់របស់ ឌុច បានទទួលរងការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃនៅមន្ទីរស-២១ ។ ស្ត្រីម្នាក់ត្រូវបានគេដាក់ឈើចូលទៅក្នុងប្រដាប់ភេទរបស់នាង ។ ចំណែកឯមិត្តភក្តិទីពីររបស់ ឌុច វិញត្រូវបានបង្ខំឲ្យស៊ីលាមកខ្លួនឯង ។ វីលៀម ស្មីត បានអះអាងថា ការបដិសេធរបស់ ឌុច ខ្វះខាតនូវភាពជឿទុកចិត្តបាន បើពិចារណាពីការបន្ថែមព័ត៌មានរបស់ ឌុច ដោយផ្ទាល់ទាក់ទិននឹងអ្នកទោសទាំងពីរនាក់នេះ ។ ជាមួយគ្នានេះ ក៏មានការសួរចម្លើយរាប់រយដែលត្រូវបានបន្ថែមព័ត៌មានទៀតផងដែរ ។ ឌុច បានបង្ហាញឲ្យឃើញពីភាពគ្មានអាណិតអាសូរបន្តិចណាឡើយចំពោះអ្នកទោសនៅមន្ទីរស-២១ ។

វីលៀម ស្មីត បានរៀបរាប់ពីការប្រព្រឹត្តដោយផ្ទាល់របស់ ឌុច នៅក្នុងការធ្វើទារុណកម្មនៅមន្ទីរម-១៣ មុនពេលផ្លាស់មកគ្រប់គ្រងមន្ទីរស-២១ ។ តាមពិត ក្នុងអំឡុងរយៈពេលប្រាំពីរឆ្នាំកន្លះ ឌុច

បានវាយដំ និងធ្វើទារុណកម្មអ្នកទោសជាច្រើននាក់ ។ ហេតុអ្វីបានជា ឌុច ប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនោះក្នុងរយៈពេលដ៏យូរបែបនេះប្រសិនបើ ឌុច មិនទទួលបានបញ្ជាឲ្យធ្វើដូច្នោះ? វីលៀម ស្មិត បានឆ្លើយតបនឹងសំណួរនេះថា នេះគឺដោយសារតែ ឌុច មានភាពជឿជាក់ខ្លាំងក្នុងការធ្វើដូច្នោះ ។ លោកក៏បាននិយាយបន្តទៀតថា “ការបង្កឲ្យមានភាពឈឺចាប់ គឺមិនមែនជាអ្វីដែល ឌុច ស្អប់នោះទេ ផ្ទុយទៅវិញ វាគឺជាអ្វីដែល ឌុច យល់ថាមានសារសំខាន់ និងពេញចិត្តនឹងធ្វើវា” ។

យោងតាម វីលៀម ស្មិត ការយកចិត្តទុកដាក់ពីសេចក្តីលម្អិតរបស់ ឌុច គឺមានលក្ខណៈគួរឲ្យ “ភ្ញាក់ផ្អើល” ដែលមាននៅក្នុងរបាយការណ៍ជូនទៅថ្នាក់លើ ។ ៩០ ភាគរយនៃអ្នកទោសរបស់មន្ទីរស-២១ បានរៀបរាប់ថា មិនបង្កគ្រោះថ្នាក់អ្វីដល់បក្សកុម្មុយនីស្តកម្ពុជាឡើយ ។ សម្រាប់អ្នកទោសមួយចំនួនធំ ឌុច បានអនុវត្តវិធីសាស្រ្តធ្វើទារុណកម្មដោយខ្លួនឯង ។ ឌុច បានបូកសរុបរបាយការណ៍សួរចម្លើយទាំងអស់សម្រាប់ជាប្រយោជន៍ដល់ថ្នាក់លើ ។ ឌុច មានការចងចាំរាល់សេចក្តីលម្អិតស្ទើរទាំងអស់ ។

នៅក្នុងព័ត៌មានបន្ថែមដែលមានក្នុងរបាយការណ៍ ឌុច បានសរសេរថា “សម្លាប់ពួកវាទាំងអស់ទៅ” “សួរចម្លើយតែបួននាក់បានហើយ ក្រៅពីនឹងសម្លាប់ទាំងអស់” “កម្ទេច” ។ ការចូលរួមរបស់ ឌុច នៅក្នុងពេលសួរចម្លើយ និងធ្វើទារុណកម្មភាគច្រើន អាចនឹងមិនមែនជាការប្រើប្រាស់ពេលវេលា ដ៏មានប្រយោជន៍របស់ ឌុច ទេ ។ បើទោះបីជាមិនប្រាកដថាមានបញ្ជាពីថ្នាក់លើក៏ដោយ ក៏ ឌុច បានចេញបញ្ជាឲ្យសម្លាប់មុនបញ្ជារបស់ថ្នាក់លើ ។ រាល់ការសម្លាប់ទាំងអស់ តែងតែទាមទារឲ្យមានការចេញបញ្ជាពី ឌុច ជាមុនសិន ។ មេដឹកនាំជាន់ខ្ពស់ មានភាពជឿជាក់លើ ឌុច ក្នុងការសម្លាប់មនុស្សទៅតាមកាលៈទេសៈដែលត្រឹមត្រូវ ។ ឌុច គឺជាដៃគូរដ៏មានឆន្ទៈមោះមុតម្នាក់ក្នុងការសម្រេចគម្រោងការណ៍ ។ ដូច្នេះ តើ ឌុច ពិតជាស្អប់ខ្ពើមនឹងកិច្ចការទាំងនេះ ហើយនិយាយថា បានធ្វើវាដោយសារតែភាពភ័យខ្លាចមែនដែរឬទេ? វីលៀម ស្មិត បានចោទសួរពីភាពអាចជឿទុកចិត្តថា តើ ឌុច អាចអនុវត្តវិធីសាស្រ្តថ្មី និងអនុវត្តតួនាទីជាសកម្មជនក្នុងដំណើរការប្រតិបត្តិរបស់មន្ទីរស-២១ និងសកម្មភាពប្រព្រឹត្តមកលើអ្នកទោស និងហេតុផលដែល ឌុច ថា ខ្លួនប្រព្រឹត្តសកម្មភាពបែបនោះ ដោយភាពភ័យខ្លាចបានដោយរបៀបណា ។

ឌុច គឺជាអ្នកមានជំនឿខ្លាំងទៅលើគោលការណ៍កុម្មុយនីស្ត ។ ប្រព័ន្ធជំនឿនោះបានផ្តល់ឲ្យ ឌុច នូវការប្តេជ្ញាចិត្តអភិវឌ្ឍន៍ និងស្ម័គ្រចិត្តបម្រើក្នុងជួរបដិវត្តន៍ ។ បើទោះបីជា ឌុច អះអាងថាមិនអាចដកខ្លួន

ចេញពីបដិវត្តន៍បានក្រោយពីឆ្នាំ១៩២១ក៏ដោយ ក៏ភស្តុតាងទាំងអស់មិនបានគូសបញ្ជាក់ថា ការអះអាងរបស់ ឌុច មានភាពត្រឹមត្រូវនោះទេ។ ហើយបើទោះបីជាមេធាវីការពារក្តីបានអះអាងថា គ្មាននរណាម្នាក់ចង់ក្លាយជាឃាតករសម្លាប់មនុស្សដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះក៏ដោយ ក៏កាលពីមុន ឌុច បានរៀបចំខ្លួនរួចជាស្រេច ដើម្បីបន្តបម្រើជូនគោលការណ៍បក្សកុម្មុយនីស្តកម្ពុជា។ ឌុច គឺជាអ្នកលះបង់បូជាជូនបក្ស ។

វីលៀម ស្មីត មានភាពងឿងឆ្ងល់ថា តើចំពោះការកោតសរសើររបស់ ឌុច ដែលមានលើ សុន សេន នោះមានន័យដូចម្តេច។ ឌុច បានអះអាងថា សុន សេន បានគម្រាមគំហែងជីវិតរបស់ ឌុច ប្រសិនបើ ឌុច មិនព្រមបំពេញកិច្ចការរបស់ខ្លួន។ ប៉ុន្តែក្រោយមកទៀត ឌុច បាននិយាយលើកតម្កើង សុន សេន ដោយសេចក្តីគោរពទៅវិញ។ វីលៀម ស្មីត ងឿងឆ្ងល់ថា តើ ឌុច មានជំនឿទុកចិត្តលើ សុន សេន ដោយរបៀបណាបើ សុន សេន នេះហើយដែលជាអ្នកបង្ខំឲ្យ ឌុច បង្កនូវភាពឈឺចាប់ និងទុក្ខទោសម្នេញលើជីវិតមនុស្សដ៏ច្រើន? លោកបាននិយាយថា ចម្លើយអាចរកឃើញបានដោយការពិតដែលថា គ្មានការគម្រាមគំហែងពី សុន សេន នោះទេ។ បុរសទាំងពីរនេះ (ឌុច និង សុន សេន) គឺជាអ្នកបម្រើនៅក្នុងសង្គ្រាមដូចគ្នា ។

វីលៀម ស្មីត បានកត់សម្គាល់ថា ដំណើរការជំនុំជម្រះសេចក្តីដែលមានរយៈពេលអូសបន្លាយដ៏យូរនេះបានអនុញ្ញាតឲ្យ ឌុច រៀបរាប់ដោយសេរីបន្ថែមទៀត។ “កាលណា ឌុច និយាយកាន់តែច្រើននោះការពិតនឹងត្រូវបានលាតត្រដាង” ។ ឌុច មាន“អារម្មណ៍សប្បាយរីករាយ” នៅក្នុងការជួបជាមួយ ប៉ុល ពត កាលពីឆ្នាំ១៩៧៨ បើទោះបីជា ប៉ុល ពត គឺជាមេគំនិតនៃអំពើសាហាវព្រៃផ្សៃក៏ដោយ ។ តាមការពិត ឌុច មានមោទនៈភាពក្នុងនាមជាប្រធានមនោគមវិជ្ជាតំណាងឲ្យមន្ទីរស-២១ ។ តើមានជនណាម្នាក់អាចមានមោទនៈភាពចំពោះមេដឹកនាំរបស់ខ្លួន ដែលចង់ឲ្យខ្លួនប្រព្រឹត្តនូវឧក្រិដ្ឋកម្មបែបនេះដោយរបៀបណាទៅ? វាគឺដោយសារតែ ឌុច ជឿជាក់លើបក្ស ហើយ ឌុច ពិតជាពេញចិត្តនឹងការងាររបស់ខ្លួនខ្លាំងណាស់ ដូច្នោះហើយបានជាបក្សមានជំនឿទុកចិត្តលើ ឌុច ។

ក្រោយមក វីលៀម ស្មីត ក៏បន្តរៀបរាប់ពីជីវិតផ្ទាល់ខ្លួនរបស់ ឌុច ដើម្បីស្វែងរកនូវការអធិប្បាយពន្យល់បន្ថែម ។ ឌុច រៀបការនៅក្នុងអំឡុងចុងឆ្នាំ១៩៧៥ បន្ទាប់ពីបានប្រព្រឹត្តសកម្មភាពធ្វើទារុណកម្ម និងសម្លាប់ជាលើកដំបូងរបស់ខ្លួននៅមន្ទីរស-២១ដែលទើបតែបង្កើតឡើងថ្មីៗ នៅទីក្រុងភ្នំពេញ ។

ប្រព្រឹត្តកម្មទាំងនេះមិនបានរារាំង ឌុច មិនឲ្យមានគ្រួសារទេ ។ ជាក់ស្តែង ឌុច បានក្លាយជាឪពុករបស់ក្មេងពីរនាក់ខណៈពេលដែល ឌុច កំពុងតែចាប់ខ្លួន និងសម្លាប់ក្មេងៗជាច្រើននៅមន្ទីរស-២១ ។ វីលៀម ស្មីត បាននិយាយទាំងសោកស្តាយថា "ឌុច ពិតជាដាច់មនុស្សធម៌មែន" ។ "ស្របពេលកំពុងតែចិញ្ចឹមបីបាច់ថែរក្សាកូនរបស់ខ្លួន ឌុច កំពុងតែបង្អត់អាហារ និងសម្លាប់ក្មេងៗដទៃផ្សេងទៀត" ។ វីលៀម ស្មីត ជឿជាក់ថា ការអធិប្បាយពន្យល់ គឺស្ថិតនៅក្នុងឥទ្ធិពលនៃតម្រូវការអ្វីមួយដើម្បីទទួលបានជំនឿទុកចិត្ត ។ ឌុច គិតថាខ្លួនឯងគឺជាអ្នកការពាររបស់បក្សមជ្ឈិម ។ ឌុច មិនអាចក្លាយជាជនបដិវត្តន៍ និងមានអារម្មណ៍អ្វីទាំងអស់ ។ លោកក៏បានលើកឡើងពីសក្ខីកម្មនៅក្នុងដំណើរការនីតិវិធីរបស់លោកសាស្ត្រាចារ្យ ដេវីត ឆេនល័រ ។ យោងតាមលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ័លរ ឌុច មានជំនឿជឿជាក់យ៉ាងមោះមុតលើការសួរចម្លើយ ។ ការសួរចម្លើយនេះ គឺជាផ្នែកមួយរបស់បក្សដែល ឌុច យល់ថាគ្មានបញ្ហាក្នុងការទទួលយកមកអនុវត្តនោះទេ ។

ប្រសិនបើឥឡូវនេះ ឌុច ទទួលស្គាល់ថាខ្លួនបានអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងមានជំនឿជឿជាក់ក្នុងការប្រព្រឹត្តបែបនោះ បើទោះបីជាមិនអះអាងថាខ្លួនស្អប់កិច្ចការទាំងនោះ រស់នៅដោយភាពភ័យខ្លាច និងគ្មានឱកាសនឹងរត់គេចខ្លួនក៏ដោយ ក៏ការទទួលស្គាល់បែបនេះកើតឡើងយឺតពេលទៅហើយ ។ ជនរងគ្រោះជាច្រើននាក់ នឹងរស់នៅជាមួយនឹងការកុហករបស់ ឌុច អស់រយៈពេលជាច្រើនឆ្នាំ ។
វីលៀម ស្មីត បានសន្និដ្ឋានបញ្ចប់ពីទស្សនៈរបស់លោកដែលមានចំពោះ ឌុច ជន ដៃដល់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាមរបស់របប ប៉ុល ពត នៅក្នុងប្រទេសកម្ពុជាថា ៖ "ឌុច គឺជាដៃគូរដ៏មានឆន្ទះមោះមុតមិនមែនដោយសារតែ ឌុច ត្រូវបានបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ ប៉ុន្តែគឺដោយសារតែ ឌុច ជឿជាក់លើភាពត្រឹមត្រូវពិតប្រាកដរបស់មេដឹកនាំទាំងនោះ ។ ឌុច គឺជាមនុស្សដែលមានភាពប៉ិនប្រសប់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ។ ឌុច មិនមែនជាអ្នកទោសរបស់របបនោះទេ ។ ឌុច មិនមែនជាជនអ្វីផ្សេងក្រៅពីអ្នកចូលរួមដ៏មានឆន្ទះក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម" ។

ក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់ វីលៀម ស្មីត, ឌុច សម្លឹងមើលតែផ្នែកខាងស្តាំ ដោយងាកមុខចេញពី វីលៀម ស្មីត ។ ភ្នែករបស់ ឌុច ក្រឡេកមើលពិដានទៅកាន់មេធាវីការពារក្តី និងកញ្ចក់កុំព្យូទ័ររបស់ខ្លួន ។ ជាក់ស្តែង ឌុច មិនហ៊ានសម្លឹងមើល វីលៀម ស្មីត ឡើយ ។ ភាគច្រើន ឌុច មើលទៅដូចជាមានភាពព្រួយបារម្ភ ក្រៀមក្រំ និងកណ្តោចកណ្តែង ។

ដោយសារតែបញ្ហាប្រព័ន្ធសម្លេង ដែលកើតឡើងនៅក្នុងដំណើរការសវនការពេលរសៀល វីលៀម ស្មីត មិនអាចបញ្ចប់សេចក្ដីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់លោកឡើយ ។ លោកនឹងបន្តធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់នេះនៅថ្ងៃពុធ ទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយបន្ទាប់ពីនេះ សហមេធាវីការពារក្ដី នឹងចាប់ផ្ដើមធ្វើសេចក្ដីសន្និដ្ឋានបន្ត ។